**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ៖ ២០១ កប/ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩

# ប្រកាស
## ស្តីពី
## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រចាំឆ្នាំ ២០១០

**រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ/បក. ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០១០

## សម្រេច

**ប្រការ១.~** ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅឆ្នាំ ២០១០ ដោយត្រូវអនុញ្ញាតឱ្យកម្មករ និយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារបានឈប់សម្រាកការងារដោយមានប្រាក់ឈ្នួលតាមការកំណត់ដូចតទៅ ៖

- បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ មករា
- ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា
- បុណ្យមាឃបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ៣០ ខែ មករា
- បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ មីនា
- បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី ១៤-១៥ និងថ្ងៃទី ១៦ ខែ មេសា
- បុណ្យវិសាខបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ២៨ ខែ មេសា
- បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ ឧសភា

- ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ គឺថ្ងៃទី ០៣ ខែ ឧសភា ជំនួសថ្ងៃទី ០២ ខែ ឧសភា ដែលចំថ្ងៃអាទិត្យ
- ព្រះរាជពិធីបុណ្យព្រះជន្មព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនបីថ្ងៃ គឺ ថ្ងៃទី ១៣-១៤ និងថ្ងៃទី ១៥ ខែ ឧសភា
- ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះមហាក្សត្រីព្រះវររាជមាតា **នរោត្តម មុនីនាថ សីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ១៨ ខែ មិថុនា
- បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញចំនួនមួយថ្ងៃ គឺថ្ងៃទី ២៤ ខែ កញ្ញា
- បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ គឺថ្ងៃទី ០៧-០៨ និងថ្ងៃទី ០៩ ខែ តុលា
- ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណាព្រះបាទសម្តេចបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនមួយថ្ងៃ គឺថ្ងៃទី ២៩ ខែ តុលា
- ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះវររាជបិតា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ វិច្ឆិកា ជំនួសថ្ងៃទី ៣១ ខែ តុលា ដែលចំថ្ងៃអាទិត្យ
- បុណ្យឯករាជ្យជាតិ ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៩ ខែ វិច្ឆិកា
- ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ចំនួនបីថ្ងៃ គឺថ្ងៃទី ២០-២២ និងថ្ងៃទី ២៣ ខែ វិច្ឆិកា ជំនួសថ្ងៃទី ២១ ខែ វិច្ឆិកា ដែលចំថ្ងៃអាទិត្យ
- បុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិ ចំនួនមួយថ្ងៃ គឺថ្ងៃទី ១០ ខែ ធ្នូ ។

**ប្រការ២.**~ ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា ១៤៧ នៃច្បាប់ស្តីពីការងារ ត្រូវឱ្យឈប់នៅថ្ងៃអាទិត្យសម្រាប់កម្មករ និងនិយោជិតទាំងអស់ ។

**ប្រការ៣.**~ ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ២១៤ កប/ប្រ.ក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤.**~ ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**វង សូត**

<u>ចម្លងជូន</u>៖

- ក្រសួងព្រះរបមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
  “ ដើម្បីជូនជ្រាប”
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  រាជធានី-ខេត្ត “ ដើម្បីផ្សព្វផ្សាយ និងអនុវត្ត ”
- សមាគមនិយោជក
- សហព័ន្ធ សហជីព កម្មករ និយោជិត
  “ ដើម្បីជ្រាប និងអនុវត្ត ”
- កាលប្បវត្តិ និងឯកសារ

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា